## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**

## សារជូនពរ

### សូមគោរពជូន

### សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត ហេង សំរិន ប្រធានរដ្ឋសភា
### នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសបុណ្យខួបកំណើតគម្រប់ ៨៣ ឈានចូល ៨៤ ឆ្នាំ

**សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត ប្រធានរដ្ឋសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់** !

ក្នុងឱកាសប្រកបដោយនក្ខត្តឫក្ស នៃពិធីបុណ្យខួបកំណើតគម្រប់៨៣ ឈានចូល ៨៤ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំ និងភរិយា សូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការ សូម **សម្តេចអគ្គមហា-ពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត** ទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេសជាតិ ប្រកបដោយនិរន្តរភាព និងភាពសម្បូរសប្បាយរុងរឿងតរៀងទៅ។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះសូម **សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត** មេត្តាអនុញ្ញាតឲ្យយើងខ្ញុំទាំងអស់គ្នាបានសម្តែងនូវសេចក្តីគោរពចំពោះគុណូបការៈដ៏ធំធេង ចំពោះគំរូវីរភាពស្នេហាជាតិមាតុភូមិ និងបានរួមចំណែកយ៉ាងសកម្មក្នុងការកសាងសមិទ្ធផលលើគ្រប់វិស័យរបស់សង្គមជាតិ ទាំងក្នុងផ្នែកពុទ្ធចក្រ និងអាណាចក្រ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់ពុទ្ធសាសនិក និងកូនចៅជំនាន់ក្រោយ ពិសេសក្នុងស្ថាប័នរដ្ឋសភា សម្រេចបានជោគជ័យដ៏ត្រចះត្រចង់ជាបន្តបន្ទាប់និងបានជំរុញឲ្យអង្គនីតិប្បញ្ញត្តិ ដែលជាស្ថាប័នកំពូលរបស់ជាតិមានការវិវឌ្ឍនរីកចម្រើនឥតឈប់ឈរជាលំដាប់។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំ និងភរិយា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមប្រោសព្រំសព្ទសាធុការពរជ័យ សិរីមង្គល ជូនចំពោះ **សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត** និង**លោកជំទាវ** ព្រមទាំង បុត្រាបុត្រី ចៅប្រុសចៅស្រី សូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ សូមជួបតែនឹងពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត ប្រធានរដ្ឋសភា** និង **លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៨ អ៊ីមែល៖ generalsec@mod.gov.kh